# សេចក្តីត្រូវការរបស់មនុស្ស ~ គោលបំណងនៅពេលអនាគតរបស់ព្រះជាម្ចាស់

# Human Need and God’s Future Intention

**សេចក្តីសង្ខេប:**

ស្ថានភាពរបស់មនុស្សបាបគឺអស់សង្ឃឹម បើគ្មានព្រះជាម្ចាស់។ គោលបំណងប្រកបដោយព្រះហឫទ័យអាណិតអាសូរ និងប្រកបដោយសិរីល្អរបស់ព្រះជាម្ចាស់សម្រាប់មនុស្សដែលបាក់បែក រួមមានការអត់ទោសអំពើបាប ការស្តារទំនាក់ទំនងរវាងមនុស្ស និងព្រះជាម្ចាស់ឡើងវិញ ព្រមទាំងការស្តារស្នាព្រះហស្តដទៃទៀតដែលបានបាក់បែកឡើងវិញ។ ព្រះអង្គបានប្រទានការផ្គត់ផ្គង់ដ៏គ្រប់លក្ខណ៍សម្រាប់ប្រោសលោះយើង និងបានសន្យាអំពីអនាគតដ៏អស្ចារ្យនៅពេលដែលព្រះយេស៊ូវយាងត្រលប់មកវិញ។

**គំនិតចម្បង:**

១. អំពើបាបបានបំបាក់បំបែកទំនាក់ទំនងរវាងមនុស្សនិងព្រះ មនុស្សនិងមនុស្ស មនុស្សនិងស្នាព្រះហស្តដែលព្រះអង្គបានបង្កើត។

២. មនុស្សបាបអស់សង្ឃឹម និងកំពុងតម្រង់ឆ្ពោះទៅរកសេចក្តីក្រោធរបស់ព្រះជាម្ចាស់។

៣. តាមរយៈការសោយទិវង្គតរបស់ព្រះយេស៊ូវ មនុស្សអាចត្រូវបានអត់ទោសឱ្យ ហើយផ្លូវបានបើកឡើង ដើម្បីស្តារទំនាក់ទំនងរបស់មនុស្សជាមួយព្រះជាម្ចាស់ និងជាមួយរបស់សព្វសារពើឡើងវិញ។

៤. ព្រះជាម្ចាស់សន្យាអំពីការកែទាំងអស់ជាថ្មីឡើងនៅពេលអនាគត នៅពេលដែលព្រះយេស៊ូវយាងមកជាលើកទីពីរ។

៥. យើងត្រូវចូលរួមនៅក្នុងការស្តារអ្វីដែលបានបាក់បែកឡើងវិញ និងប្រកាសដំណឹងល្អនេះ រហូតដល់ព្រះយេស៊ូវយាងត្រលប់មកវិញ។

**លទ្ធផល:**

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តជំហានថ្មីមួយជាការឆ្លើយតបទៅនឹងគំនិតចម្បងនៅក្នុងមេរៀននេះ ដើម្បីចូលរួមនៅក្នុងការស្តារឡើងវិញនូវអ្វីដែលបានបាក់បែក ដោយសារការមិនស្តាប់បង្គាប់ /អំពើបាបរបស់មនុស្ស។

២. ទៅមុខទៀត

ក. ទទួលស្គាល់ថា ព្រះជាម្ចាស់មានផែនការឱ្យមនុស្សចូលរួមជាមួយព្រះអង្គនៅក្នុងការស្តារឡើងវិញនូវទំនាក់ទំនងដែលបានបាក់បែករវាងមនុស្ស និងព្រះជាម្ចាស់ រវាងមនុស្ស និងមនុស្ស រវាងមនុស្ស និងរបស់សព្វសារពើ រហូតដល់ព្រះអង្គយាងត្រលប់មកវិញ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីប្រាប់គោលបំណងរបស់ព្រះជាម្ចាស់ ដើម្បីផ្សះផ្សាឡើងវិញទំនាក់ទំនងទាំងអស់ដែលបានបាក់បែក និងបំផុសអ្នកជឿឱ្យចូលរួមជាមួយព្រះជាម្ចាស់នៅក្នុងគោលបំណងនេះ រហូតដល់ព្រះគ្រីស្ទយាងត្រលប់មកវិញ។

# សេចក្តីត្រូវការរបស់មនុស្ស ~ គោលបំណងនៅពេលអនាគតរបស់ព្រះជាម្ចាស់

## គ្រោងមេរៀន

## ១. រំឭកមេរៀនឡើងវិញ

## ២. សេចក្តីផ្តើម

## ៣. ខគម្ពីរគន្លឹះៈ រ៉ូម ១:២១

ក. តើអ្វីដែលបានផ្លាស់ប្តូរការវាយតម្លៃរបស់ព្រះជាម្ចាស់ថា "ល្អប្រពៃ" (លោកុ ១:៣១) ទៅជាព្រះអង្គស្តាយដែលបានបង្កើតមនុស្ស (លោកុ ៦:៦)?

ខ. តើលោកអ្នកគិតថា ការវាយតម្លៃមួយណាដែលឆ្លុះបញ្ចាំងពីស្ថានភាពរបស់មនុស្សនៅសព្វថ្ងៃនេះ?

## ៤. តើបទគម្ពីរទាំងនេះនិយាយយ៉ាងដូចម្តេចអំពីស្ថានភាពរបស់មនុស្សដែលគ្មានព្រះជាម្ចាស់?

- លោកុប្បត្តិ ៦:៥
- រ៉ូម ៣:២៣
- អេភេសូរ ២:១

- រ៉ូម ២:៥

## ៥. តើព្រះជាម្ចាស់មានឥរិយាបថយ៉ាងដូចម្ដេចចំពោះមនុស្សដែលបាក់បែក?

- យ៉ូហាន ៣:១៧

- ភីលីព ២:៥-១១

## ៦. តើគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគតមានអ្វីខ្លះ?

- អេសាយ ១១:៤-៩

- អេសាយ ៦១:១-៤

- យ៉ូហាន ១៤:១-៤

- រ៉ូម ៨:២១

- វិវរណៈ ២១:១-៤

- ម៉ាថាយ ១៩:២៨

## ៧. ការពង្រឹងគំនិតគន្លឹះឡើងវិញ

## ៨. ការអនុវត្តន៍

ក. ការឆ្លុះបញ្ចាំងផ្ទាល់ខ្លួន

- តើលោកអ្នកអាចមើលឃើញភាពបាក់បែកអ្វីខ្លះនៅជុំវិញលោកអ្នក និងសហគមន៍របស់លោកអ្នក?

- តើយើងម្នាក់ៗផ្ទាល់ខ្លួន និងជាពួកជំនុំ ចែកចាយដំណឹងល្អអំពីគោលបំណងសម្រាប់ពេលអនាគតរបស់ព្រះជាម្ចាស់ដល់អ្នកដែលកំពុងតែឈឺចាប់នៅក្នុងសហគមន៍របស់យើងបានល្អដល់កម្រិតណា?

- តើលោកអ្នកអាចតំណាងឱ្យគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគតជាមួយមនុស្សទាំងនេះបានយ៉ាងដូចម្ដេច?

- តើដំណឹងល្អនេះពាក់ព័ន្ធអ្វីខ្លះសម្រាប់អ្នកដែលកំពុងរងទុក្ខវេទនានៅពេលឥឡូវនេះ?

ខ. ការប្ដេជ្ញាចិត្ត និងផែនការ: ចូរធ្វើគម្រោងផែនការអនុវត្តជាក់លាក់មួយ ដើម្បីជួយមនុស្សនៅក្នុងសហគមន៍របស់លោកអ្នកនៅក្នុងផ្នែកមួយនៃផ្នែកទាំងនេះ ឱ្យគេមើលឃើញគោលបំណងសម្រាប់ពេលអនាគតរបស់ព្រះជាម្ចាស់ តាមរយៈការបម្រើពួកគេ។

- ថ្មី
- ពិតប្រាកដ
- ជាក់លាក់ ( អ្វី នរណា នៅពេលណា នៅកន្លែងណា)
- ចែកចាយ

| | |
|---|---|
| <u>*គួររង្វង់ជុំវិញផ្នែក*</u><br><br>**ប្រាជ្ញា**<br><br>**ខាងសាច់ឈាម**<br><br>**ខាងវិញ្ញាណ**<br><br>**ខាងសង្គម** | **អ្វីៈ**<br><br>**នរណាៈ**<br><br>**នៅពេលណាៈ**<br><br>**នៅកន្លែងណាៈ** |

# សេចក្តីត្រូវការរបស់មនុស្ស ~ គោលបំណងនៅពេលអនាគតរបស់ព្រះជាម្ចាស់

## មេរៀន

### ភាពបាក់បែករបស់មនុស្ស

តើលោកអ្នកបានឃើញ បានឮ និងបានជួបប្រទះឧទាហរណ៍អ្វីខ្លះអំពីភាពបាក់បែករបស់មនុស្សនៅសប្តាហ៍នេះ? តើលោកអ្នកបានឃើញបញ្ហាខាងសាច់ឈាមអ្វីខ្លះ? តើមានជម្ងឺអ្វីខ្លះ? តើមានសេចក្តីស្លាប់ដែរឬទេ? ឬតើមានភាពក្រីក្រដែរឬទេ? តើលោកអ្នកបានជួបប្រទះបញ្ហាខាងវិញ្ញាណអ្វីខ្លះ? តើមានវិញ្ញាណអាក្រក់អ្វីខ្លះ? តើមានការថ្វាយបង្គំរូបព្រះដែរឬទេ? ឬតើមានអំពើពុករលួយដែរឬទេ? តើលោកអ្នកបានឃើញបញ្ហាសង្គមអ្វីខ្លះ? តើមានការបាក់បែកទំនាក់ទំនងអ្វីខ្លះ? តើមានអំពើអយុត្តិធម៌នៅក្នុងសង្គមអ្វីខ្លះ? តើមានអ្វីផ្សេងទៀតដែរឬទេ? ភស្តុតាងអំពីភាពបាក់បែកមាននៅគ្រប់ទីកន្លែង! នៅពេលដែលយើអានសារព័ត៌មាន មើលទូរទស្សន៍ ឬសម្លឹងមើលអ្វីដែលកំពុងកើតឡើងនៅជុំវិញយើង យើងមើលឃើញឧទាហរណ៍យ៉ាងច្រើនអំពីភាពបាក់បែក។

រ៉ូម ១:២១ ជួយយើងឱ្យយល់អំពីភាពបាក់បែករបស់មនុស្សជាតិៈ

> ព្រោះកាលគេបានស្គាល់ព្រះ នោះគេមិនបានដំកើងទ្រង់ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ គេកើតមានគំនិតឥតប្រយោជន៍វិញ ហើយចិត្តគេដែលឥតយោបល់ ក៏បានត្រឡប់ជាងងឹតទៅ។

បទគម្ពីរនេះបង្ហាញរូបភាពអស់សង្ឃឹមរបស់មនុស្សដែលបាក់បែក។ នេះគឺជាទិដ្ឋភាពមួយផ្សេងពីទិដ្ឋភាពដែលយើងបានឃើញនៅក្នុងលោកុប្បត្តិ ១:៣១ នៅពេលដែលព្រះជាម្ចាស់បានទតមើលស្នាព្រះហស្តដែលព្រះអង្គបានបង្កើត ហើយមានបន្ទូលថា "ល្អប្រពៃ"។ ប៉ុន្តែ ពីរបីជំពូកក្រោយមក នៅក្នុងលោកុប្បត្តិ ៦:៦ ព្រះគម្ពីរប្រាប់យើងថា ព្រះជាម្ចាស់*សោកស្តាយ* ដែលព្រះអង្គបានបង្កើតយើង។ តើអ្វីទៅដែលបានផ្លាស់ប្តូរការវាយតម្លៃរបស់ព្រះជាម្ចាស់? នោះគឺជាការមិនស្តាប់បង្គាប់ គឺមនុស្សមិនបានរស់នៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ។

នេះគឺជាសេចក្តីពិត ហើយការមិនស្តាប់បង្គាប់មិនមែនមានតែនៅក្នុងកណ្ឌគម្ពីរលោកុប្បត្តិប៉ុណ្ណោះទេ។ នៅក្នុងព្រះគម្ពីរទាំងមូល មនុស្សដែលព្រះជាម្ចាស់បានបង្កើតបានបះបោរទាស់នឹងផ្លូវរបស់ព្រះអង្គ។ ប្រសិនបើយើងស្មោះ

ត្រង់ចំពោះខ្លួនឯង យើងដឹងថា នេះគឺជាស្ថានភាពនៃពិភពលោករបស់យើងនៅសព្វថ្ងៃនេះ។ យើងមិនស្តាប់បង្គាប់។ យើងមិនបានរស់នៅតាមផែនការរបស់ព្រះជាម្ចាស់ និងតាមដែលព្រះអង្គត្រាស់ហៅយើងឱ្យរស់នៅទេ។

ស្ថានភាពរបស់មនុស្សគ្មានព្រះជាម្ចាស់គឺងងឹតសូន្យសុង។ យើងមើលឃើញស្ថានភាពនោះនៅជុំវិញខ្លួនយើង ឬ នៅពេលដែលយើងអានព័ត៌មាន ហើយព្រះគម្ពីរបញ្ជាក់អះអាងអំពីស្ថានភាពនោះ។ លោកុប្បត្តិ ៦:៥ ប្រាប់យើងថា អស់ទាំងគំនិតក្នុងចិត្តគេក៏សុទ្ធតែអាក្រក់ជានិច្ច។ រ៉ូម ៣:២៣ រំលឹកយើងថា យើងទាំងអស់គ្នាបានធ្វើបាប ហើយខ្វះមិនដល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ អេភេសូរ ២:១ ប្រាប់ថា យើងរាល់គ្នាក៏ស្លាប់ក្នុងការរំលង ហើយក្នុងអំពើបាបដោយគ្មានព្រះជាម្ចាស់។ ចុងក្រោយ រ៉ូម ២:៥ ប្រាប់យើងថា ដោយគ្មានការអន្តរាគមន៍របស់ព្រះជាម្ចាស់ យើងនឹងទៅរកសេចក្តីក្រោធរបស់ព្រះអង្គ។

នៅពេលដែលកំពុងបង្រៀនមេរៀននេះ យើងមើលបទគម្ពីរទាំងនេះ បន្ទាប់មកឱ្យសិស្សបំបែកទៅជាក្រុមតូច ហើយក្រុមតូចនិមួយៗយកក្រដាសមួយសន្លឹក គូររូបភាពមួយនៅពាក់កណ្តាលផ្នែកខាងក្រោមតំណាងឱ្យស្ថានភាពរបស់មនុស្សដែលគ្មានព្រះជាម្ចាស់។ យើងលើកទឹកចិត្តពួកគេមានឱ្យមានគំនិតឆ្នៃប្រឌិត។ យើងត្រូវយល់ឱ្យបានពេញលេញអំពីស្ថានភាពបាក់បែករបស់មនុស្ស។ តើលោកអ្នកនឹងពន្យល់បង្ហាញតាមរូបភាពអំពីស្ថានភាពបាក់បែករបស់មនុស្សដែលគ្មានព្រះជាម្ចាស់យ៉ាងដូចម្តេច?

មែនហើយ ស្ថានភាពរបស់មនុស្សដែលគ្មានព្រះជាម្ចាស់បាក់បែក ប៉ុន្តែព្រះជាម្ចាស់មិនចង់ឱ្យយើងនៅតែបាក់បែកនោះទេ។ នៅក្នុងយ៉ូហាន ៣:១៧ យើងរៀនថា ព្រះយេស៊ូវបានយាងមកដើម្បីជួយសង្គ្រោះ មិនមែនដើម្បីដាក់ទោសមនុស្សបាក់បែកទេ។ ភីលីព ២:៥-១១ រំលឹកយើងថា ព្រះគ្រីស្ទគឺជាអ្នកបម្រើដែលព្រមលះបង់ចោលទាំងអស់ ហើយយាងមកសុគតជំនួសមនុស្សបាក់បែក។ ព្រះរបស់យើងអស្ចារ្យខ្លាំងណាស់។ ព្រះអង្គមានផែនការដើម្បីប្រោសលោះភាពបាក់បែករបស់យើង។ នេះគឺពិតជាដំណឹងល្អសម្រាប់មនុស្សទាំងអស់។

## គោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត

ព្រះគម្ពីរក៏បញ្ជាក់ប្រាប់ផងដែរថា ព្រះជាម្ចាស់មានផែនការដ៏អស្ចារ្យសម្រាប់ពេលអនាគត។ នៅក្នុងអេសាយ ១១:៤-៩ មាននិមិត្តអំពីសន្តិភាព និងភាពបរិបូរ។ នៅក្នុងអេសាយ ៦១:១-៤ យើងត្រូវបានប្រាប់ថា យើងនឹងចូលរួមស្អាងរបស់សព្វសារពើឡើងវិញ។ នៅក្នុងយ៉ូហាន ១៤:១-៤ យើងឮថា ព្រះយេស៊ូវបានយាងទៅដើម្បីរៀបចំកន្លែងសម្រាប់យើង។ រ៉ូម ៨:២១ បញ្ជាក់អះអាងប្រាប់យើងថា របស់សព្វសារពើទាំងអស់នឹងត្រូវបានរំដោះចេញពីចំណងដែលបានកើតឡើងនៅក្នុងការធ្លាក់ចុះ។ នៅក្នុងវិវរណៈ ២១:១-៤ យើងបានអានអំពីអនាគតកាលមួយដ៏មាន

សោភ័ណភាព ដែលគ្មានសេចក្តីស្លាប់ ទឹកភ្នែក និងការឈឺចាប់ទៀតទេ។ ចុងបញ្ចប់ ម៉ាថាយ ១៩:២៨ ប្រាប់យើងថា ព្រះយេស៊ូវនឹងយាងត្រលប់មកវិញជាស្តេច។ ព្រះជាម្ចាស់មានផែនការសម្រាប់ពេលអនាគត ហើយផែនការនោះលើសជាងដែលយើងអាចនឹកស្មានដល់!

នៅពេលកំពុងបង្រៀនមេរៀននេះ ក្រោយពីយើងបានពិនិត្យមើលបទគម្ពីរទាំងនេះរួចហើយ នោះសូមឱ្យសិស្សត្រលប់ទៅតាមក្រុមតូចរបស់ពួកគេវិញ ដើម្បីពន្យល់បង្ហាញតាមរយៈរូបភាពនូវអ្វីដែលពួកគេបានមើលឃើញនៅក្នុងបទគម្ពីរអំពីផែនការរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត។ ដោយប្រើក្រដាសតែមួយដែលមានរូបភាពទីមួយនៅពាក់កណ្តាលផ្នែកខាងលើ សិស្សគូររូបភាពពន្យល់មួយផ្សេងទៀតតំណាងឱ្យសេចក្តីដែលបទគម្ពីរទាំងនេះប្រាប់អំពីគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត។ តើលោកអ្នកនឹងគូររូបអ្វី? ក្រុមជាច្រើនបានគូររូបភាពដែលពិបាកយល់មកពណ៌នាគោលបំណងរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត។ រូបភាពពន្យល់ដ៏សាមញ្ញមួយសម្រាប់ចំណុចនេះ គឺរូបមូលពងក្រពើដែលលក្ខណៈស្រ៊ុឌិ ដោយមានពាក្យដែលពណ៌នាអំពីផែនការរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត គឺគ្មានសេចក្តីស្លាប់ សន្តិភាព ភាពបរិបូរ ព្រះជាម្ចាស់គង់នៅជាមួយយើង។

រូបភាពដែលបានគូររួចហើយទាំងនេះឆ្លុះបញ្ចាំងឱ្យឃើញពីភាពផ្ទុយគ្នារវាងស្ថានភាពបាក់បែករបស់មនុស្សដែលគ្មានព្រះជាម្ចាស់ និងគោលបំណងដ៏អស្ចារ្យរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត។ នៅក្នុងស្ថានភាពបាក់បែករបស់យើង គ្រប់ទាំងគំនិតគិតរបស់មនុស្សសុទ្ធតែអាក្រក់ ហើយគ្រប់គ្នាបានធ្វើបាប ខ្វះមិនដល់បំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។ មនុស្សដែលគ្មានព្រះជាម្ចាស់អស់សង្ឃឹម។ ពិតណាស់ អ្នកដែលមិនប្រែចិត្តធ្វើដំណើរឆ្ពោះទៅរកសេចក្តីក្រោធរបស់ព្រះជាម្ចាស់។

***ប៉ុន្តែ...***ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូវមកដើម្បីជួយសង្គ្រោះយើង មិនមែនដើម្បីដាក់ទោសយើងទេ។ នឹងមានសន្តិភាព និងភាពបរិបូរ។ យើងនឹងចូលរួមនៅក្នុងការស្អាងឡើងវិញនូវរបស់សព្វសារពើដែលបានបាក់បែក។ ព្រះយេស៊ូវកំពុងរៀបចំកន្លែងមួយសម្រាប់យើង។ នៅថ្ងៃមួយ ស្នាព្រះហស្តទាំងអស់នឹងត្រូវបានរំដោះឱ្យរួចពីភាពបាក់បែករបស់ខ្លួន។ ព្រះជាម្ចាស់មិនត្រឹមតែស្រលាញ់មនុស្សដែលព្រះអង្គបានបង្កើតប៉ុណ្ណោះទេ ផែនការសម្រាប់ពេលអនាគតរបស់ព្រះអង្គរួមមានការប្រោសរបស់សព្វសារពើទាំងអស់ឱ្យបានជា។ ស្នាព្រះហស្តរបស់ព្រះអង្គដែលឥឡូវនេះបាក់បែកនៅថ្ងៃមួយនឹងត្រូវបានរំដោះចេញពីចំណងរបស់ខ្លួន ហើយរ៉ូម ៨:១៩-២០ ប្រាប់យើងថា ការរំដោះឱ្យមានសេរីភាពនេះនឹងត្រូវបានចងភ្ជាប់ទៅនឹង"សេរីភាពដ៏រុងរឿង"នៃកូនរបស់ព្រះជាម្ចាស់។ នឹងគ្មានសេចក្តីស្លាប់ ការឈឺចាប់ ឬទឹកភ្នែកទៀតទេ។ ព្រះយេស៊ូវនឹងយាងត្រលប់មកវិញជាស្តេចលើអស់ទាំងស្តេច! គ្រប់ទាំងសាសន៍នឹងមើលឃើញ ស្តាប់បង្គាប់តាម និងទទួលបានព្រះពរប្រកបដោយសិរីល្អរបស់ព្រះអង្គ។ វិវរណៈ ២១:២៤ ប្រាប់យើងថា " អស់ទាំង

សាសន៍នឹងដើរក្នុងពន្លឺក្រុងនោះ អស់ទាំងស្ដេចនៅផែនដីក៏យកសិរីនៃខ្លួនមកទុកក្នុងក្រុងនោះដែរ"។ របៀបវារៈរបស់ព្រះជាម្ចាស់រួមមានការប្រោសមនុស្សដែលបានបាក់បែក និងរបស់សព្វសារពើដែលបានបាក់បែកឱ្យបានជា រួមបញ្ចូលសាសន៍ទាំងឡាយផងដែរ។

តើនេះជាដំណឹងល្អដែរឬទេ? មែនហើយ នេះគឺជាដំណឹងដែលអស្ចារ្យខ្លាំងណាស់! ប៉ុន្តែអ្វីដែលយើងធ្វើជាមួយដំណឹងល្អនេះមានសារៈសំខាន់ខ្លាំងណាស់។ យើងអាចរស់នៅក្នុងភាពងងឹតសូន្យសុងរបស់ភាពបាក់បែក ហើយរង់ចាំការប្រោសលោះនៅពេលអនាគត ឬយើងអាចចូលរួមនៅក្នុងនិមិត្តរបស់ព្រះជាម្ចាស់សម្រាប់ពេលអនាគត។

នេះគឺជារឿងមួយសម្រាប់ពន្យល់អត្ថន័យនេះ។ ពីរបីឆ្នាំមុន លោកបប់ ម៉ូហ្វិត កំពុងតែទស្សនៈកិច្ចនៅក្នុងទីក្រុងលីម៉ា ប្រទេសពេរូ។ គាត់បានជួបបុរសវ័យក្មេងម្នាក់ឈ្មោះ រូឌី។ នៅពេលថ្មីៗនេះ រូឌី បានក្លាយទៅជាអ្នកជឿ ហើយជីវិតរបស់គាត់ត្រូវបានបំផ្លាស់បំប្រែទាំងស្រុង។ រូឌី មានវណ្ណៈកណ្ដាល ហើយគាត់មានចិត្តអាណិតអាសូរដល់អ្នកក្រ។ គាត់ចង់ចែកចាយដំណឹងល្អដល់ពួកគេខ្លាំងណាស់។

គាត់បានសម្រេចចិត្តធ្វើកិច្ចការមួយ។ ដូច្នេះ នៅថ្ងៃមួយ គាត់បានជិះឡានក្រុងទៅកន្លែងរស់នៅរបស់អ្នកក្រនៅជាយក្រុងលីម៉ា ដោយមានខិតប័ណ្ណពេញមួយហោប៉ៅ។ គាត់បានចុះពីឡានក្រុង ដើរតម្រង់ទៅឯបុរសវ័យក្មេងម្នាក់ដែលគាត់បានឃើញ។ រូឌីបាននិយាយថា "សួស្ដី ខ្ញុំឈ្មោះរូឌី។ តើបងឈ្មោះអ្វីដែរ?"។ បុរសនោះបានឆ្លើយថា "ខ្ញុំឈ្មោះជូអាន"។ រូឌីបានសួរថា "តើបងធ្វើអ្វីនៅទីនេះ?"។ ជូអានបានឆ្លើយថា "ខ្ញុំគ្មានការងារធ្វើទេ ខ្ញុំឃ្លាន ខ្ញុំមានបញ្ហាគ្រប់បែបយ៉ាងទាំងអស់"។ គាត់បានយកខិតប័ណ្ណមួយសន្លឹកចេញពីហោប៉ៅ ហើយនិយាយថា "ខិតប័ណ្ណនេះនឹងប្រាប់បងអំពីដំណោះស្រាយសម្រាប់បញ្ហារបស់បង"។ បុរសវ័យក្មេងនោះបាននិយាយថា "ខ្ញុំមិនត្រូវការខិតប័ណ្ណរបស់បងទេ។ ខ្ញុំដឹងថា ខិតប័ណ្ណនេះនិយាយអំពីអ្វីហើយ។ ខិតប័ណ្ណនេះនិយាយអំពីព្រះយេស៊ូវ។ ខ្ញុំមិនត្រូវការព្រះយេស៊ូវរបស់បងទេ"។ រូឌីបានឆ្លើយថា "ប៉ុន្តែ ព្រះយេស៊ូវអាចដោះស្រាយបញ្ហារបស់បងបាន! ព្រះអង្គចង់ឱ្យបងនៅជាមួយព្រះអង្គអស់កល្បជានិច្ច"។ ជូអានបាននិយាយថា "ឥឡូវនេះ ខ្ញុំត្រូវការអាហារ"។ រូឌីបានប្រាប់ជូអានថា "ព្រះយេស៊ូវគឺជានំប៉័ងជីវិត! សូមអានខិតប័ណ្ណនេះទៅ។ ខិតប័ណ្ណនេះពិតជានឹងជួយបងមិនខាន"។ នៅទីបញ្ចប់ ជូអាន បាននិយាយថា "ខ្ញុំចង់បង្ហាញប្រាប់បងថា ខ្ញុំគិតយ៉ាងដូចម្ដេចអំពីព្រះយេស៊ូវ"។ គាត់បានយកខិតប័ណ្ណនោះមក ហែកទៅជាចំរៀកតូចៗ ហើយដាក់នៅក្នុងមាត់របស់គាត់។ ខណៈពេលដែលរូឌីសម្លឹងមើលដោយស្រឡាំងកាំង ជូអានបានទំពារខិតប័ណ្ណយ៉ាងយឺតៗ ហើយលេបបាត់ទៅ។ គាត់បានប្រាប់រូឌីថា "ខ្ញុំបានប្រាប់បងរួចហើយ! ខ្ញុំមិនត្រូវការព្រះយេស៊ូវរបស់បងទេ។ ខ្ញុំត្រូវការអាហារ!"។

នៅពេលដែលរូឌីប្រាប់រឿងនេះដល់បប់ ទឹកភ្នែកបានហូរចុះមក។ គាត់បាននិយាយថា "ខ្ញុំបានយល់ច្បាស់ថា ខ្ញុំមិនអាចប្រាប់អ្នកក្រអំពីព្រះយេស៊ូវបានទេ លើកលែងតែខ្ញុំអាចនាំយកអាហារទៅដែរ"។ ដូច្នេះ រូឌី បានជួបជុំមិត្តភក្តិរបស់គាត់ ហើយពួកគេបានចាប់ផ្តើមហាងដុតនំមួយកន្លែង។ ពួកគេបានលក់នំប៉័ង។ តាមរយៈចំណូលរបស់ពួកគេ ពួកគេបានយកនំប៉័ងទៅកន្លែងដែលអ្នកក្ររស់នៅ។ ពួកគេបានចែកនំប៉័ង និងបានប្រាប់មនុស្សអំពីព្រះយេស៊ូវ។ ខ្ញុំគិតថា ជូអាន មានសារដែលពួកយើងជាច្រើននាក់ត្រូវស្តាប់ឮ។ ពិភពលោកបានបាក់បែកយ៉ាងខ្លាំង។ ហើយមនុស្សបាក់បែកកំពុងតែនិយាយថា "ខ្ញុំដឹងថា អ្នកមានដំណឹងល្អសម្រាប់ពេលអនាគត ប៉ុន្តែតើមិនមានដំណឹងល្អសម្រាប់ខ្ញុំនៅពេលឥឡូវនេះទេឬ?"។

មាន! អំពើបាបបានមកកាត់ផ្តាច់បំណងល្អរបស់ព្រះជាម្ចាស់សម្រាប់ពិភពលោក ប៉ុន្តែផែនការរបស់ព្រះជាម្ចាស់គឺស្តារគោលបំណងរបស់ព្រះអង្គឱ្យបានពេញលេញឡើងវិញ។ ការប្រោសឱ្យជានៅពេលអនាគតមិនទាន់មកដល់នៅឡើយទេ ប៉ុន្តែក៏មានហេតុផលដើម្បីនឹងផ្តល់សេចក្តីសង្ឃឹមសម្រាប់ការប្រោសឱ្យជា និងការស្តារឡើងវិញនៅក្នុងពេលបច្ចុប្បន្នផងដែរ។ ព្រះជាម្ចាស់ត្រាស់ហៅប្រជារាស្ត្ររបស់ព្រះអង្គឱ្យបង្ហាញចេញនៅពេលបច្ចុប្បន្ននេះអំពីរាជ្យនៅពេលអនាគតរបស់ព្រះគ្រីស្ទ។ ការស្តារដ៏ពេញលេញនឹងកើតឡើង ក្រោយពីព្រះគ្រីស្ទយាងត្រលប់មកវិញ ប៉ុន្តែនៅពេលឥឡូវនេះ ប្រជារាស្ត្ររបស់ព្រះជាម្ចាស់មានការទទួលខុសត្រូវសម្រេចបំណងព្រះហឫទ័យរបស់ព្រះអង្គនៅទីនេះ "នៅលើផែនដីដូចជានៅស្ថានសួគ៌ដែរ" ដើម្បីពង្រីករាជ្យរបស់ព្រះអង្គនៅលើផែនដី និងកាន់កាប់"ទឹកដី"[១]រហូតដល់ព្រះអង្គយាងត្រលប់មកវិញ។

ព្រះជាម្ចាស់បានប្រទានឱ្យប្រជារាស្ត្ររបស់ព្រះអង្គមានឱកាសចូលរួមនៅក្នុងគោលបំណងដ៏ធំជាងគេនៅក្នុងប្រវត្តិសាស្ត្រ។ ព្រះអង្គអនុញ្ញាតឱ្យយើងធ្វើជាអ្នកមើលខុសត្រូវ។ ការប្រព្រឹត្តិរបស់យើងមានឥទ្ធិពលលើភាពអស់កល្បជានិច្ច។ គ្រប់ទាំងកិច្ចការដែលយើងធ្វើស្របតាមបំណងព្រះហឫទ័យរបស់ព្រះអង្គសុទ្ធតែមានសារៈសំខាន់។ ស្ត្រីមេម៉ាយដែលបានដាក់តង្វាយពីរកាក់នៅព្រះវិហារ មិនបាននឹកស្មានដល់ថា តង្វាយរបស់នាងមានឥទ្ធិពលរយៈពេលជាងពីរពាន់ឆ្នាំទេ។ យើងក៏កំពុងតែធ្វើឱ្យមានឥទ្ធិពលដែលនឹងទៅដល់ជំនាន់ក្រោយៗទៀត លើសពីអ្វីដែលយើងអាចដឹង ឬមើលឃើញនៅពេលនេះ។ ប្រសិនបើមនុស្សនៅក្នុងពួកជំនុំរបស់យើងអាចយល់បានអំពីទំនាក់ទំនងរវាងជីវិត

[1] លូកា ១៩:១៣

របស់ពួកគេ និងគោលបំណងដ៏អស្ចារ្យដែលព្រះជាម្ចាស់មានសម្រាប់មនុស្សជាតិ ទាំងនៅពេលបច្ចុប្បន្ន និងនៅពេលអនាគត ពួកគេនឹងយល់ថា គ្មានបុព្វហេតុណាសម្រាប់ឱ្យពួកគេរស់នៅ ឬស្លាប់[២] ធំជាងបុព្វហេតុនេះទៀតទេ ។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ 85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាត: លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១០០០ ច្បាប់ ។*

[២] សេចក្តីជាច្រើននៅក្នុងអត្ថបទនេះដកស្រង់ដោយផ្ទាល់ចេញពី *ប្រសិនបើព្រះយេស៊ូវគឺជាចៅហ្វាយក្រុង* និពន្ធដោយ បប់ ម៉ូហ្វិត ។ យកមកប្រើដោយមានការអនុញ្ញាតិ ។

## ធនធានល្អដែលបានផ្តល់ជាយោបល់ជូនៈ

Harvest Website www.harvestfoundation.org Sections: ??

Disciple Nations Alliance online course: www.disciplenations.org/resources/course. Section: Wholistic Ministry

*If Jesus Were Mayor*, Bob Moffitt and Karla Tesch, Chapter 5 pp. 31-34; 75-86.

On Earth?

Background papers?